**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

លេខ : ✓ មស.

## លិខិតជូនពរ

**សូមគោរពជូន**

**ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់

ក្នុងឱកាសចម្រើនជន្មាយុគម្រប់៧១ឆ្នាំ ឈានចូល៧២ឆ្នាំ របស់ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ** នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១នេះ យើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈទាំងអស់ សូមសម្ដែងការចូលរួមអបអរសាទរ និងគោរពជូនពរយ៉ាងកក់ក្ដៅចំពោះ **ឯកឧត្តម** សូមប្រកបដោយសុខភាពល្អបរិបូរណ៍ កាយពលមាំមួន បញ្ញាញាណវាងវៃ និងមានជន្មាយុយឺនយូរ។

ឆ្លៀតក្នុងឱកាសដ៏ឧត្ដុង្គឧត្ដមនេះ យើងខ្ញុំសូមអនុញ្ញាតសម្ដែងនូវទឹកចិត្តយ៉ាងថ្លៃថ្លា និងការដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះសកម្មភាពជាគំរូរបស់ **ឯកឧត្តម** នៅក្នុងបេសកកម្មដឹកនាំទីស្ដីការគណៈរដ្ឋមន្ត្រី សម្រេចបាននូវសមិទ្ធផលជាច្រើនជាប្រវត្តិសាស្ត្រដើម្បីបម្រើជាតិ និងប្រជាជន រួមចំណែកយ៉ាងសំខាន់ដល់ការរក្សាបាននូវសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍប្រកបដោយចីរភាព។

ជាថ្មីម្ដងទៀត ក្នុងនាមថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការក្រសួងមុខងារសាធារណៈ សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមប្រោសប្រទានពរជ័យ សិរីសួស្ដី ជ័យមង្គល វិបុលសុខបវរមហាប្រសើរ ជូន **ឯកឧត្តម និងលោកជំទាវ ព្រមទាំង បុត្រា បុត្រី ចៅប្រុស ចៅស្រី** សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត** មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅ និងខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ។

ថ្ងៃ អង្គារ ៩ កើត ខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០២១
**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ញ៉ឹម-សុខា

ផ្លូវវេត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh